**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ១២ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ
## ក្រោមប្រធានបទ "ភាពស្អិតរមួត និង ការឆ្លើយតបនៃអាស៊ាន"
## ថ្ងៃទី ១២- ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០

ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ក្រោមប្រធានបទ **"ភាពស្អិតរមួត និង ការឆ្លើយតបនៃអាស៊ាន"** តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រោមប្រធានបទ **"ភាពស្អិតរមួត និង ការឆ្លើយតបនៃអាស៊ាន"**, កិច្ចប្រជុំកំពូលនេះ ត្រូវបានរៀបចំឡើងដោយផ្តោតការពិភាក្សាទៅលើផលប៉ះពាល់ទៅលើវិស័យសុខភាពសាធារណៈ និងសង្គម-សេដ្ឋកិច្ចរបស់ប្រទេសនៅក្នុងតំបន់ ដែលបណ្តាលមកពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩, ការកំណត់ទិសដៅបន្ទាប់ក្នុងការស្តារ និងរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក និងតំបន់ នៅពេលដែលវិបត្តិនេះត្រូវបញ្ចប់ ។ កិច្ចប្រជុំកំពូលនេះ ក៏ជាវេទិកាដ៏សំខាន់ សម្រាប់ថ្នាក់ដឹកនាំអាស៊ាន និងភាគីពាក់ព័ន្ធទាំងអស់ ធ្វើការផ្លាស់ប្តូរយោបល់ និងផ្តល់ជាធាតុចូលក្នុងការដោះស្រាយលើបញ្ហាសំខាន់ៗ នៅក្នុងតំបន់ និងសកល ព្រមទាំងដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើចំពោះគំនិតផ្តួចផ្តើមដែលបានបង្កើតថ្មី និងដែលមានស្រាប់ ក្នុងន័យពង្រឹងស្មារតីពហុភាគីនិយម និងការរក្សាបាននូវអព្យាក្រឹត្យភាពរបស់អាស៊ាន ។

នាព្រឹកថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ នេះ, នៅក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៧, ឯកឧត្តម **ង្វៀន ស្វួនហ្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានបង្ហាញពីគោលជំហររបស់ប្រទេសវៀតណាម ក្នុងការពង្រឹងប្រសិទ្ធភាពស្ថាប័ន,ការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩, ការស្តារ និងងើបឡើងវិញនៃសង្គម-សេដ្ឋកិច្ច និងបានអំពាវនាវឱ្យប្រទេសអាស៊ានទាំងអស់ប្រកាន់ខ្ជាប់នូវការរក្សាបាននូវមជ្ឈភាព និងសាមគ្គីភាពរបស់អាស៊ាន ព្រមទាំង តុល្យភាពរបស់អាស៊ាន នៅចំពោះមុខការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងមហាអំណាចនៅក្នុងតំបន់ ។

ពាក់ព័ន្ធទៅនឹងជំងឺកូវីដ-១៩, ឯកឧត្តម **តេដ្រូស អ៊ែតហានូ ហ្គេប្រេយ៉េសស៊ុស** អគ្គនាយកនៃអង្គការសុខភាពពិភពលោក បានធ្វើបទបង្ហាញខ្លីស្តីពីស្ថានភាពជំងឺកូវីដ-១៩ និងបានបញ្ជាក់ថាជំងឺកូវីដ-១៩ មិនទាន់មានភាពថមថយនៅឡើយទេ ដែលនេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវរក្សាការប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងចូលរួមយ៉ាងសកម្មជាមួយគ្នាក្នុងការស្វែងរកនូវយន្តការ និងឧបករណ៍ថ្មី ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះ ក៏ដូចជាការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ក្រោយពីវិបត្តិនៃជំងឺនេះ ។

ក្នុងនាមព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អ៊ុន ព័ន្ធមុនីរ័ត្ន** បានចូលរួមបទអន្តរាគមន៍ដោយផ្តោតជាសំខាន់ទៅលើការប្តេជ្ញាចិត្តដ៏មុតមាំ និងការសន្យារបស់កម្ពុជាទៅលើចក្ខុវិស័យរួមគ្នារបស់អាស៊ានក្នុងទិសដៅសម្រេចឱ្យបាននូវសមាហរណកម្មរួម ប្រកបដោយភាពរឹងមាំ និងវិបុលភាព តាមរយៈកិច្ចសហប្រតិបត្តិការ, សាមគ្គីភាព និងប្រកាន់ខ្ជាប់នូវសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងយន្តការពហុភាគីនិយម ។

កិច្ចប្រជុំកំពូលអាស៊ានលើកទី ៣៧ នេះ ក៏បានអនុម័តដាក់ឱ្យដំណើរការនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃឡើងវិញពាក់កណ្តាលអាណត្តិលើផែនការលម្អិតនៃសហគមន៍អាស៊ានឆ្នាំ ២០២៥, ក្របខណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន និងស្តុកបម្រុងបរិក្ខារពេទ្យតំបន់អាស៊ាន ។

កិច្ចប្រជុំកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ បានចាប់ផ្តើមពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ នឹងបន្តកិច្ចពិភាក្សារហូតដល់ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ។